លេខ:៤៣ សគកង រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០០៨

# លិខិតចំហជូនចំពោះអ្នកតំណាងរាស្ត្រទាំង ១២៣ រូប
# ស្តីពីការបង្កើតរាជរដ្ឋាភិបាលថ្មីអាណត្តិទី ៤ ខាងមុខនេះ

សម្តេច ព្រះអង្គម្ចាស់ លោកជំទាវ ឯកឧត្តម ជាអ្នកតំណាងរាស្ត្រជាទីគោរព !

ជួសមុខឱ្យបុគ្គលិកសិក្សា និង មន្ត្រីរាជការរាប់ម៉ឺននាក់នៅទូទាំងប្រទេសកម្ពុជា ។ ហើយក្នុងនាមខ្ញុំប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ ខ្ញុំសូមសម្តែងនូវការគោរពដ៏ស្មោះត្រង់ និង ភាពកតញ្ញូតាធមិដ៏ជ្រាលជ្រៅចំពោះសម្តេច ព្រះអង្គម្ចាស់ លោកជំទាវ ឯកឧត្តម ជាអ្នកតំណាងរាស្ត្រ ខណៈពេលបង្កើតរាជរដ្ឋាភិបាលថ្មីខាងមុខនេះ ក្នុងគម្រោងសមាជិកគណៈរដ្ឋមន្ត្រីមានរហូតដល់ចំនួន **៣៩២**នាក់ មិនធ្លាប់មានទេ ប្រទេសក្នុងពិភពលោក ដែលគណៈរដ្ឋមន្ត្រីមួយមានក្បាលធំ ជាងខ្លួន ។

ខ្ញុំសូមអនុញ្ញាតទាញអារម្មណ៍អ្នកតំណាងរាស្ត្រទាំងអស់ ទៅលើគណៈរដ្ឋមន្ត្រី ដែលមានក្បាលធំជាងខ្លួន គ្រោងនឹងដាក់ស្នើសុំឱ្យរដ្ឋសភាផ្តល់នូវសេចក្តីអនុម័តនាពេលខាងមុខនេះ ដែលមានចំនួន ឧបនាយករដ្ឋមន្ត្រី**០៩នាក់** ទេសរដ្ឋមន្ត្រី **១៦**នាក់ រដ្ឋមន្ត្រី **២៦**នាក់ រដ្ឋលេខាធិការ **១៧២**នាក់ និង អនុរដ្ឋលេខាធិការ **១៦៨**នាក់ ។ ចំនួនសមាជិកគណៈរដ្ឋមន្ត្រីសម្រាប់អាណត្តិទី៤ ដ៏ច្រើនលើសលប់ វាមិនមែនឆ្លុះបញ្ចាំងនូវអភិបាលកិច្ចល្អ សម្រាប់ស្ថាប័នទាំងអស់នោះទេ គ្រាន់តែជាការការពារអំណាចរបស់ខ្លួន និង ការចំណាយថវិកាជាតិច្រើនឥតប្រយោជន៍ ហើយក៏មិនមែនជាកំណែទម្រង់ស៊ីជំរៅ ដែលរដ្ឋាភិបាលមួយមានក្បាលធំជាងខ្លួននោះដែរ ។

ចំពោះបញ្ហានេះ អ្នកតំណាងរាស្ត្រគ្រប់រូប ដែលតំណាងឱ្យរាស្ត្រពិតប្រាកដនោះ ត្រូវពិចារណាអំពីការបំប៉ោងសមាជិកគណៈរដ្ឋមន្ត្រីរបស់រាជរដ្ឋាភិបាលអាណត្តិទី៤ មុននឹងផ្តល់ការអនុម័ត ។ រដ្ឋាភិបាលត្រូវកាត់បន្ថយចំនួនសមាជិកគណៈរដ្ឋមន្ត្រី ដែលច្រើនមកចំនួនមួយសមល្មម ដើម្បីជៀសវាងចំណាយថវិកាជាតិខ្ជះខ្ជាយច្រើនឥតប្រយោជន៍ គឺត្រូវប្រមូលថវិកាជាតិទាំងនោះ យកមកតម្លើងប្រាក់ខែជូនគ្រូបង្រៀន មន្ត្រីរាជការ នគរបាល និង ទាហាន ឱ្យពួកគេមានជីវភាពរស់នៅសមរម្យ ប្រសើរជាងយកទៅចំណាយលើគណៈរដ្ឋមន្ត្រី ដែលមានក្បាលធំជាងខ្លួន ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានបីអាណត្តិមកហើយ បន្ទាប់ពីអង្គការសហប្រជាជាតិ បានរៀបចំឱ្យមានការបោះឆ្នោតនៅឆ្នាំ១៩៩៣ កន្លងមកនេះ ។ ប៉ុន្តែបញ្ហាប្រាក់ខែរបស់គ្រូបង្រៀន មន្ត្រីរាជការ នគរបាល និង ទាហាន រដ្ឋាភិបាលមិនបានដោះស្រាយ ហើយឥឡូវនេះក្នុងខណៈតម្លៃអតិផរណាទីផ្សារខ្ពស់ បានធ្វើឱ្យគ្រូបង្រៀន មន្ត្រី

រាជការ  នគរបាល និង ទាហានមានប្រាក់ខែទាប បាននឹងកំពុងទទួលរងសម្ពាធយ៉ាងខ្លាំងពីតម្លៃទំនិញខ្ពស់នេះ ។ ប្រាក់ខែរបស់ពួកគេមានគម្លាតឆ្ងាយណាស់ ពីប្រាក់ខែរបស់សមាជិករាជរដ្ឋាភិបាល និង សមាជិករដ្ឋសភា ។ ដើម្បីឱ្យគ្រប់ស្ថាប័នទាំងអស់ មានអភិបាលកិច្ចល្អ រាជរដ្ឋាភិបាលអាណត្តិទី៤នេះ ត្រូវផ្តល់ដំណោះស្រាយមុនគេ គឺតម្លើងប្រាក់ខែជូនគ្រូបង្រៀន មន្ត្រីរាជការ នគរបាល និង ទាហាន កុំឱ្យគម្លាតឆ្ងាយពីប្រាក់បំណាច់ប្រចាំខែរបស់សមាជិករាជរដ្ឋាភិបាល និងសមាជិករដ្ឋសភា និង ឱ្យមានតុល្យភាពនឹងតម្លៃទំនិញទីផ្សារ ។

ដូច្នេះខ្ញុំសង្ឃឹមថា សម្តេច ព្រះអង្គម្ចាស់ លោកជំទាវ ឯកឧត្តម ជាអ្នកតំណាងឱ្យរាស្ត្រពិតប្រាកដ នឹងពិនិត្យពិចារណា មុនអនុម័តផ្តល់សេចក្តីទុកចិត្តលើសមាជិកគណៈរដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលអាណត្តទី៤ មិនឱ្យក្បាលធំជាងខ្លួន ជៀសវាងការចំណាយ ថវិកាជាតិច្រើនឥតប្រយោជន៍ ។

សូមសម្តេច ព្រះអង្គម្ចាស់ លោកជំទាវ ឯកឧត្តមទទួលការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

**ប្រធាន**

**[ហត្ថលេខា]**